**សុន្ទរកថា**

**ឯកឧត្តម ព្រុំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ**

**និងជាប្រធានអនុគណៈកម្មាធិការមុខងារ និងធនធាន នៃ គ.ជ.អ.ប**

**ក្នុងពិធីបើកសិក្ខាសាលាពិគ្រោះយោបល់ស្តីពី**

**កិច្ចដំណើរការផ្ទេរមុខងារទៅក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ ២០១១

**សណ្ឋាគារ ភ្នំពេញ**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី!**

ជាបឋម ខ្ញុំសូមសម្តែងនូវកិច្ចស្វាគមន៍យ៉ាងរាក់ទាក់ និងកក់ក្តៅបំផុតចំពោះឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាតំណាងក្រសួង ស្ថាប័ននានានៃរាជរដ្ឋាភិបាល តំណាងរដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងតំណាងអង្គការសង្គមស៊ីវិលទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីអញ្ជើញមកចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីកិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិដ៏មានសារសំខាន់នាថ្ងៃនេះ។

សិក្ខាសាលានាថ្ងៃនេះ គឺជាការជួបជុំគ្នាលើកទីមួយក្នុងចំណោមតំណាងក្រសួង ស្ថាប័ននៅថ្នាក់ជាតិ តំណាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធសំខាន់ៗនានា ដើម្បីពិភាក្សា អំពី គោលការណ៍ជាគន្លឹះ កិច្ច ដំណើរការ យន្តការគាំទ្រដល់ការរៀបចំ ផ្ទេរមុខងារ និងធនធាន ព្រមទាំងតម្រូវការនៃការអភិវឌ្ឍសមត្ថភាព សម្រាប់អនុវត្ត មុខងារនានា ដែលនឹងត្រូវផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ យោបល់ និងអនុសាសន៍នានាដែលប្រមូលបានពីអង្គសិក្ខាសាលានេះ នឹងត្រូវធ្វើជាមូលដ្ឋានសម្រាប់ការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំបច្ចេកទេស នានាសម្រាប់គាំទ្រដល់កិច្ចដំណើរការនៃការផ្ទេរមុខងារ និងធនធានទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។

កំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ បានចាប់ផ្តើមជាមួយការបង្កើតឡើងនូវក្រុមប្រឹក្សាឃុំ សង្កាត់ តាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ជាលើកដំបូងនាខែកុម្ភៈ ឆ្នាំ២០០២។ ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនេះ គឺជាអង្គភាពអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ តំណាងឲ្យសម្លេងឆន្ទៈ និងផលប្រយោជន៍របស់ប្រជាជននៅមូលដ្ឋាន។ រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាចិត្តខាងនយោបាយយ៉ាងមុតមាំក្នុងការគាំទ្រដល់កិច្ចដំណើរការនៃប្រព័ន្ធអភិបាលកិច្ចថ្មីនេះ តាមរយៈការផ្តល់ស្វ័យភាពខាងធនធានហិរញ្ញវត្ថុ ការអនុវត្តការងារ និងសមត្ថភាពចាំបាច់នានា ដើម្បីក្រុមប្រឹក្សាឃុំ

សង្កាត់ អាចចាប់ផ្តើមធ្វើការផ្តល់សេវា និងការអភិវឌ្ឍន៍មូលដ្ឋានស្របតាមតម្រូវការជាអាទិភាពនានារបស់មូលដ្ឋាននីមួយៗ លើមូលដ្ឋាននៃការចូលរួម និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋនៅមូលដ្ឋានរបស់ខ្លួន ដែលជាការរួមចំណែកយ៉ាងសំខាន់ជួយដល់រាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាប្រឈមនានានៅមូលដ្ឋានប្រកបដោយភាពបត់បែន និងមានលក្ខណៈសមស្របតាមស្ថានភាពជាក់ស្តែងរបស់មូលដ្ឋាននីមួយៗ។ ប្រព័ន្ធអភិបាលកិច្ចថ្មីនេះ បានទទួលការគាំទ្រ និងការចូលរួមយ៉ាងទូលំទូលាយពីសង្គមទាំងមូល។

សមិទ្ធផលដែលសម្រេចបាននៅថ្នាក់ឃុំ សង្កាត់ បានផ្តល់ភស្តុតាង និងលើកទឹកចិត្តដល់រាជរដ្ឋាភិបាល ដើម្បីពង្រីកដំណើរការកំណែទម្រង់នេះទៅថ្នាក់រដ្ឋបាលក្រោមជាតិទាំងមូល។

នៅឆ្នាំ២០០៥ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលជាក្របខ័ណ្ឌគោលនយោបាយកំណត់នូវគោលការណ៍ជាគន្លឹះនានាសម្រាប់រៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធអភិបាលកិច្ចថ្មីនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សំដៅពង្រីកវិសាលភាពនៃប្រព័ន្ធគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ នៅរដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូល ដែលរាជរដ្ឋាភិបាលបានកំណត់ថា នេះជាដំណើរការនៃការកែទម្រង់សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ ផ្អែកលើគោលនយោបាយនេះ ច្បាប់រៀបចំអង្គការត្រូវបានអនុម័តដាក់ឲ្យប្រើប្រាស់នៅឆ្នាំ២០០៨ បានផ្តល់នូវមូលដ្ឋានគតិយុត្តសម្រាប់កំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ និងបានបង្កើតឲ្យមានក្រុមប្រឹក្សានៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌតាមរយៈការបោះឆ្នោតអសកលនាឆ្នាំ២០០៩។ ដូច្នេះ រហូតមកដល់ពេលនេះ ផ្អែកតាមក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ ប្រព័ន្ធអភិបាលកិច្ចតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិទាំងមូល ត្រូវបានដាក់ជំនួសរួចទៅហើយនូវប្រព័ន្ធគ្រប់គ្រងដែលធ្លាប់បានអនុវត្តនៅមុនពេលមានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទោះបីបច្ចុប្បន្នយើងកំពុងប្រឈមជាមួយការរៀបចំឡើងវិញជាជំហានៗនូវប្រព័ន្ធអភិបាលកិច្ចថ្មី ជាមួយតម្រូវការឲ្យមានការផ្លាស់ប្តូរទម្លាប់ និងឥរិយាបទក្នុងបែបផែនអភិបាលកិច្ចថ្មីនេះក្តី។ នេះជាដំណើរការកំណែទម្រង់ដ៏សាំញ៉ាំ និងរសើប ដែលទាមទារឲ្យមានការពិគ្រោះយោបល់ ការពិភាក្សាស្រុះស្រួលគ្នាពីក្នុងចំណោមក្រសួង ស្ថាប័ននានា និងពីគ្រប់តួអង្គពាក់ព័ន្ធនានា។ ដើម្បីសម្របសម្រួល និងគាំទ្រដល់ដំណើរការកំណែទម្រង់នេះ ច្បាប់រៀបចំអង្គការបានតម្រូវឲ្យបង្កើតគណៈកម្មាធិការអន្តរក្រសួងមួយ គឺគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ។

កំណែទម្រង់នេះមិនគ្រាន់តែមានការប៉ះពាល់មកលើស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិប៉ុណ្ណោះទេ ប៉ុន្តែស្ថាប័ននានានៅថ្នាក់ជាតិ ក៏មានផលប៉ះពាល់ពីដំណើរការកំណែទម្រង់នេះផងដែរ។ ដូចនេះដើម្បីកំណត់ចក្ខុវិស័យ គោលដៅ គោលបំណង សកម្មភាព និងដំណាក់កាលនានាក្នុងរយៈពេលវែង គ.ជ.អ.ប បានរៀបចំតាក់តែងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

សម្រាប់រយៈពេល១០ឆ្នាំ (២០១០ -២០១៩) ហើយដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជា កាលពីខែឧសភា ឆ្នាំ២០១០កន្លងទៅនេះ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី!**

ខ្ញុំជឿជាក់ថា ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ មានការយល់ដឹងរួចហើយ អំពីកម្មវិធីជាតិរយៈពេល១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និង ផែនការអនុវត្តរយៈពេល៣ឆ្នាំដំបូងនៃកម្មវិធីជាតិ (២០១១ -២០១៣) ដែលយើងហៅតាត់ថា **ផអ៣**។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមធ្វើការគូសបញ្ជាក់ឡើងវិញនូវសមាសធាតុទាំង៥នៃកម្មវិធីជាតិ ដែលយើង បានស្រុះស្រួលគ្នា ហើយដែលបាននិងកំពុងអនុវត្តក្នុងផែនការអនុវត្ត៣ឆ្នាំដំបូង ដែលរួមមាន៖

- **មួយ**៖ ការបង្កើតស្ថាប័ននានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- **ពីរ** ៖ ការអភិវឌ្ឍប្រព័ន្ធ ការគ្រប់គ្រង់ធនធានមនុស្ស និងការកសាងសមត្ថភាព
- **បី** ៖ ការផ្ទេរមុខងារ និងធនធាន
- **បួន** ៖ ការបង្កើតប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- **ប្រាំ** ៖ ការរៀបចំប្រព័ន្ធគាំទ្រកំណែទម្រង់

ជិតពេញមួយឆ្នាំ២០១១នេះ យើងទាំងអស់គ្នាបានពុះពារឆ្លងកាត់ដំណាក់កាលដ៏ស្មុគស្មាញ ក្នុងការចាប់ផ្តើមអនុវត្តសមាសធាតុទាំងប្រាំខាងលើនេះ ជាមួយសមិទ្ធផលគួរឲ្យកត់សម្គាល់ ដើរទន្ទឹម នឹងបញ្ហាប្រឈមនានាដែលលេចចេញពីដំណើរការកំណែទម្រង់នេះ។

រាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈយ៉ាងមោះមុត និងបានគិតគូរពិចារណាយ៉ាងប្រុងប្រយ័ត្នក្នុងការ ប្រកាន់យកនូវយុទ្ធសាស្ត្រអនុវត្តជាជំហានៗ ផ្អែកលើបទពិសោធន៍ដែលមានកន្លងមក និងស្ថានភាព ជាក់ស្តែងនៃតម្រូវការរបស់មូលដ្ឋាន ដើម្បីធ្វើឲ្យសម្រេចបាននូវគោលបំណងនៃកំណែទម្រង់នេះ។ ជា ជំហានដំបូង យើងកំពុងចាប់ផ្តើមពង្រឹងលើការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រង ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស និងសមត្ថភាពស្ថាប័ននៅថ្នាក់ក្រុង ស្រុក ដែលជាថ្នាក់រដ្ឋបាល មូលដ្ឋានដ៏មានសារសំខាន់មួយ និងមានសក្តានុពលខ្ពស់ក្នុងការផ្តល់សេវាសាធារណៈ រួមចំណែកដល់ ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងការពង្រឹងអភិបាលកិច្ចមូលដ្ឋានក្នុងបែបផែននៃកិច្ចសហប្រតិបត្តិការ និងការ គាំទ្របច្ចេកទេសដល់ឃុំ សង្កាត់។ ជាបន្តបន្ទាប់ យើងនឹងត្រូវរៀបចំបង្កើតនូវក្របខ័ណ្ឌគតិយុត្តសម្រាប់ រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ រួមមានការរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រង ប្រព័ន្ធហិរញ្ញវត្ថុ ប្រព័ន្ធគ្រប់ គ្រងធនធានមនុស្ស ប្រព័ន្ធគាំទ្របច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើឲ្យរដ្ឋបាលទាំងនេះអាចមានលទ្ធភាព និងសមត្ថភាពក្នុងការអនុវត្តមុខងារផ្តល់សេវាសាធារណៈ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដែលបច្ចុប្បន្ននេះ មុខងារផ្តល់សេវាទាំងនេះភាគច្រើនស្ថិតនៅក្នុង សមត្ថកិច្ចរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិ។

ថ្ងៃនេះយើងនឹងបន្តធ្វើការពិគ្រោះយោបល់គ្នាបន្ថែមទៀត លើវិធីសាស្ត្រជាក់ស្តែងនៃការអនុវត្ត សមាសធាតុទីបីនៃកម្មវិធីជាតិ នោះគឺការផ្ទេរមុខងារ និងធនធាន។ លេខាធិការដ្ឋាន គ.ជ.អ.ប បាន ត្រៀមរៀបចំការងារនេះដោយសហការជាមួយក្រសួងពាក់ព័ន្ធសំខាន់ៗមួយចំនួនរួមមាន ក្រសួងអប់រំ ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច ជាមួយនឹងការគាំទ្រពីទីប្រឹក្សាជាតិ និងអន្តរជាតិ ដើម្បីរៀបចំ ក្របខ័ណ្ឌគោលការណ៍ យុទ្ធសាស្ត្រ និងដំណាក់កាលនានា សម្រាប់គាំទ្រដល់កិច្ចដំណើរការផ្ទេរមុខ ងារ និងធនធាន។ យើងបំពេញការងារនេះដោយប្រុងប្រយ័ត្ន និងដោយផ្អែកលើស្ថានភាពជាក់ស្តែង នៃសង្គម សេដ្ឋកិច្ច និងសមត្ថភាពធនធានមនុស្សរបស់យើង ជាមួយការរៀនសូត្របទពិសោធន៍ពី ប្រទេសផ្សេងៗទៀត ទាំងនៅក្នុង និងនៅក្រៅតំបន់ ដើម្បីបង្ការកុំឲ្យមានការខុសឆ្គង និងត្រៀម លក្ខណៈបង្ការជាមុននូវបញ្ហាប្រឈម និងការគ្រប់គ្រងហានិភ័យនានា ដែលអាចលេចចេញពីដំណើរ ការផ្ទេរមុខងារ និងធនធាននេះ ឲ្យស្ថិតនៅក្នុងកម្រិតមួយដែលអាចគ្រប់គ្រង និងដោះស្រាយបាន។

ការងារនេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាមូលដ្ឋាននានា ដូចជា ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលបាន ផ្តល់ការណែនាំអំពីទស្សនៈទានសំខាន់ៗទាក់ទងនឹងការលើកកម្ពស់ ប្រសិទ្ធភាពនៃការផ្តល់សេវា និងការអភិវឌ្ឍនៅមូលដ្ឋាន ច្បាប់រៀបចំអង្គការដែលបានចង្អុលបង្ហាញអំពី ក្របខ័ណ្ឌច្បាប់ និងគោលការណ៍ចម្បងៗសម្រាប់ការអនុវត្ត។ ជាមួយគ្នានេះ កម្មវិធីជាតិសម្រាប់ការ អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងផែនការអនុវត្តរយៈពេលបីឆ្នាំដំបូងនៃកម្មវិធី ជាតិ(ផអ៣) គឺជាឯកសារមូលដ្ឋានសម្រាប់គាំទ្រផ្នែកកម្មវិធី និងបច្ចេកទេសក្នុងការអនុវត្ត។ លើសពី នេះទៀត គ.ជ.អ.ប ដែលមានអនុគណៈកម្មាធិការមុខងារ និងធនធាន ព្រមទាំងអនុគណៈកម្មាធិការ នានា និងលេខាធិការដ្ឋានរបស់ខ្លួននឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្របសម្រួល គាំទ្រ ពិនិត្យមើល និងផ្តល់ការណែនាំបន្ថែមក្នុងពេលអនុវត្តជាក់ស្តែង។

ទោះបីជាយ៉ាងណាក៏ដោយ ក៏ក្នុងអំឡុងពេលអនុវត្ត ទាមទារឲ្យមានការបន្តរក្សាការប្តេជ្ញាចិត្ត លើបញ្ហានានាដែលបានព្រមព្រៀងគ្នា ដោយសារតែនិន្នាការនេះបានធ្វើឲ្យមានការផ្លាស់ប្តូរនូវរបៀប ផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាលជូនដល់ប្រជាពលរដ្ឋ ដែលតម្រូវឲ្យមានការផ្លាស់ប្តូរទាំង កម្រិតបុគ្គល និងទាំងកម្រិតស្ថាប័ន។

នៅក្រោមក្របខ័ណ្ឌនៃកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រសួង ស្ថាប័ននានានៅថ្នាក់ជាតិត្រូវពិនិត្យ មើលឡើងវិញអំពីតួនាទី ភារកិច្ច និងកិច្ចប្រតិបត្តិការរបស់ខ្លួន។ ក្នុងកិច្ចដំណើរការផ្ទេរមុខងារ និង ធនធាន តួនាទីស្នូលរបស់ក្រសួង ស្ថាប័ននឹងមានការផ្លាស់ប្តូរមួយចំនួនលើមុខងារដែលបានផ្ទេរ។ការ ផ្លាស់ប្តូរជាចម្បងនោះគឺក្រសួង ស្ថាប័ននឹងប្រែក្លាយពីអ្នកធ្លាប់ប្រតិបត្តិលើមុខងារដែលបានផ្ទេរ មកជា ស្ថាប័នរៀបចំគោលនយោបាយជាតិ រៀបចំផែនការយុទ្ធសាស្ត្រ កំណត់ស្តង់ដារជាតិ បណ្តុះបណ្តាល

កសាងសមត្ថភាព តាមដាន និងត្រួតពិនិត្យការផ្តល់សេវា និងការធានាឲ្យមានអភិបាលកិច្ចល្អជាដើម។ យើងក៏ត្រូវធានាផងដែរថា កម្មវិធីកំណែទម្រង់ទាំងបីរបស់រាជរដ្ឋាភិបាលត្រូវបានសម្របសម្រួលជាមួយគ្នា ដើម្បីគាំទ្រដល់ក្រសួង ស្ថាប័នក្នុងដំណើរការផ្លាស់ប្តូរដ៏សំខាន់នេះ និងដើម្បីសម្រេចនូវគោលបំណងរួមប្រកបដោយប្រសិទ្ធភាពខ្ពស់។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី!**

ក្របខ័ណ្ឌច្បាប់ ក្របខ័ណ្ឌគោលនយោបាយជាយុទ្ធសាស្ត្រ និងកម្មវិធីជាតិ សុទ្ធតែបានតម្រូវឲ្យមានការរៀបចំកិច្ចដំណើរការផ្ទេរមុខងារ និងធនធានក្នុងលក្ខណៈជាប្រព័ន្ធ ប្រកបដោយសនិទានភាព មានការសម្របសម្រួល ការពិគ្រោះយោបល់ និងមានតម្លាភាព។ ឯកឧត្តម **លេង វី** អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានក្រសួងមហាផ្ទៃ និងជាអនុប្រធានទី១នៃលេខាធិការដ្ឋាន គ.ជ.អ.ប នឹងបង្ហាញអំពីខ្លឹមសារនៃសេចក្តីព្រាងអំពីគោលការណ៍ និងកិច្ចដំណើរការសំខាន់ៗ និងយន្តការគាំទ្រការរៀបចំផ្ទេរមុខងារ និងធនធានក្នុងពេលបន្តិចទៀតនេះ។

ដូចខ្ញុំបានបញ្ជាក់ជូនពីខាងដើម គោលបំណងសំខាន់ៗនៃអង្គសិក្ខាសាលារបស់យើងនាឱកាសនេះ គឺដើម្បីពិនិត្យ ពិភាក្សា និងផ្តល់យោបល់លើគោលការណ៍ យុទ្ធសាស្ត្រ និងដំណើរការនៃការផ្ទេរមុខងារ ដែលបានដាក់ជូនអង្គសិក្ខាសាលាពិភាក្សា។ បន្ទាប់ពីអង្គសិក្ខាសាលានេះ អនុគណៈកម្មាធិការមុខងារ និងធនធានរបស់ គ.ជ.អ.ប ដែលមានជំនួយការពីលេខាធិការដ្ឋាន គ.ជ.អ.ប នឹងបន្តពិចារណាដោយយកចិត្តទុកដាក់ លើរាល់មតិយោបល់ដែលបានស្នើឡើងដោយអង្គសិក្ខាសាលា សម្រាប់ជាមូលដ្ឋានរៀបចំលិខិតបទដ្ឋានគតិយុត្តក្នុងទម្រង់ជាអនុក្រឹត្យ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសេចក្តីណែនាំបច្ចេកទេស នានាសម្រាប់គាំទ្រដល់ការអនុវត្តតាមជំហាននានានៃកិច្ចដំណើរការផ្ទេរមុខងារនេះ ដើម្បីដាក់ជូន គ.ជ.អ.ប ពិនិត្យ ផ្តល់គោលការណ៍ណែនាំ និងសម្រេច។

ផ្អែកលើគោលបំណងនេះ ខ្ញុំសូមឯកឧត្តម លោកជំទាវ អស់លោក លោកស្រី សមាជិកសមាជិកានៃអង្គសិក្ខាសាលា និងអ្នកពាក់ព័ន្ធទាំងអស់ សូមមេត្តាយកអស់ស្មារតីផ្តល់កិច្ចសហការស្វែងយល់ ពិភាក្សា និងផ្តល់អនុសាសន៍ជូនអង្គសិក្ខាសាលា ដើម្បីជំរុញដល់កិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាកិច្ចការស្នូលមួយនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឲ្យប្រព្រឹត្តទៅដោយរលូន។

ជាថ្មីម្តងទៀត ក្នុងនាម គ.ជ.អ.ប និងអនុគណៈកម្មាធិការមុខងារ និងធនធាន ខ្ញុំសូមថ្លែងអំណរគុណចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីក្នុងសិក្ខាសាលានេះ និងសូមប្រកាសបើកអង្គសិក្ខាសាលាពិគ្រោះយោបល់ស្តីពីកិច្ចដំណើរការផ្ទេរមុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិនេះ ចាប់ពីពេលនេះតទៅ។

**សូមអរគុណ**